វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី១៧ ខែសីហា ២០១៨**

---

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀតនៅក្នុងសប្តាហ៍នេះ គឺ៖

- ការនាំចេញរបស់កម្ពុជាកើនឡើង១៥%នៅក្នុងរយៈពេល៦ខែដំបូងឆ្នាំ២០១៨ ខណៈពេលដែលការវិនិយោគផ្នែករដ្ឋបាលចាប់ផ្តើមជះឥទ្ធិពល
- ធនាគារកណ្តាលរបស់ថៃ៖ ចំនួនមនុស្សចាស់នឹងអាចប៉ះពាល់ដល់កំណើនផ.ស.ស.
- ប្រជាជនអាមេរិកធ្វើការច្រើនជាងមុន ដោយទទួលបានប្រាក់កម្រៃតិចជាងមុនក្នុងកំឡុងឆ្នាំចុងក្រោយ

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារ បណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធ របស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ការនាំចេញរបស់កម្ពុជាកើនឡើង១៥%នៅក្នុងរយៈពេល៦ខែដំបូងឆ្នាំ២០១៨ នៅពេលដែលការវិនិយោគចាប់ផ្តើម ជះឥទ្ធិពល

ការនាំចេញរបស់កម្ពុជានៅក្នុងកំឡុងពេល៦ខែដំបូងមានតម្លៃស្មើនឹង៦,២ ប៊ីលានដុល្លារអាមេរិច គឺកើនឡើង១៥% បើធៀបនឹង៦ខែដំបូងឆ្នាំមុន។ ទំនិញដែលនាំចេញសំខាន់គឺ ផលិតផលសម្លៀកបំពាក់ ស្បែកជើង កាបូប កៅស៊ូ អង្ករ ដំឡូងមី និងផលិតផលកសិកម្មដ៏ទៃទៀត។ ទីផ្សារសំខាន់បំផុតរបស់កម្ពុជាគឺ សហភាពអឺរ៉ុប អាមេរិក កាណាដា ជប៉ុន ចិន និងប្រទេសជាសមាជិកអាស៊ាន។ តួលេខពាណិជ្ជកម្មនេះ ត្រូវបានប្រកាសដោយរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មនៅក្នុងឱកាស ប្រគល់សញ្ញាប័ត្រ សម្រាប់កម្មសិក្សាការីចំនួន១១៤នាក់ ដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលនៅវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវពាណិជ្ជកម្ម កម្ពុជា។ កម្មវិធីនេះ គឺជាផ្នែកមួយនៃការវិនិយោគដ៏ធំទូលាយ ក្នុងការកែសម្រួលរដ្ឋបាលនៅក្នុងវិស័យនាំចេញ-នាំចូល។ រដ្ឋាភិបាលបានចាត់ទុកកិច្ចការវិនិយោគនេះជាការ ចូលរួមចំណែកយ៉ាងច្រើននៅក្នុងដំណើរការពាណិជ្ជកម្មថ្មីៗនេះ។

### តារាងប្រចាំសប្តាហ៍៖ អត្រាអ្នកអត់ការងារធ្វើនៅកម្ពុជា ពីឆ្នាំ ២០០០ ទៅ២០១៧

តារាងខាងក្រោមបង្ហាញពីអត្រាអ្នកអត់ការងារធ្វើនៅកម្ពុជា ពីឆ្នាំ ២០០០ ទៅឆ្នាំ២០១៧។ នៅដើមឆ្នាំ២០០០ អត្រាអ្នកអត់ការងារធ្វើមានចំនួន២% ប៉ុន្តែអត្រានេះបានធ្លាក់ចុះមកត្រឹម០,២% ក្នុងឆ្នាំ២០១៧ គឺជាតួលេខមួយដែលទាបគួរអោយកត់សម្គាល់។ សម្រាប់ស្ត្រី អត្រាអ្នកអត់ការងារធ្វើ មានចំនួនទាបជាងអត្រាសម្រាប់ប្រជាជនទូទៅ ប៉ុន្តែនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ អត្រានេះមានការកើនឡើង ប្រហាក់ប្រហែលអត្រាអ្នកអត់ការងារធ្វើសរុប។

**អត្រាអ្នកអត់ការងារធ្វើនៅកម្ពុជា ចំនួនសរុប និងចំណែករបស់ស្ត្រី**




ប្រភព៖ [ទិន្នន័យស្ថិតិការងាររបស់ធនាគារពិភពលោក](), ធ្វើបច្ចុប្បន្នភាពចុងក្រោយនៅថ្ងៃទី៣១ សីហា ២០១៨ (ប៉ាន់ស្មានដោយILO)

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ធនាគារកណ្តាលរបស់ថៃ៖ ចំនួនមនុស្សចាស់នឹងអាចប៉ះពាល់ដល់កំណើនផ.ស.ស.

[ធនាគារជាតិរបស់ថៃ]() បានព្យាករណ៍ថា ចំនួនមនុស្សចាស់នៅប្រទេសថៃនឹងកាត់បន្ថយកំណើនផ.ស.ស.ប្រចាំឆ្នាំ១.៥%ពិន្ទុភាគរយ នៅកំឡុងពេល១០ឆ្នាំបន្ទាប់។ នៅពេលដែលកំណើនពលកម្មមានអត្រា៥%ជាមធ្យម ហើយរំពឹងថានឹងធ្លាក់ចុះមកត្រឹម ៣,៥ % នៅទសវត្សរ៍បន្ទាប់។

ចំនួនប្រជាជនដែលមានអាយុលើសពី៦៥ឆ្នាំនៅប្រទេសថៃ មានចំនួន៧%នៃចំនួនប្រជាជនសរុប។ អត្រានេះនឹងរំពឹងថាកើនឡើងទៅ១៣%ត្រឹមឆ្នាំ២០២០ ដែលអត្រានេះត្រូវបានអង្គការសហប្រជាជាតិចាត់ទុកថាជា "បញ្ហាសង្គមមនុស្សចាស់"។ នៅក្នុងតំបន់អាស៊ាន ថៃជាប្រទេសដែលមានចំនួនមនុស្សចាស់ច្រើនជាងគេ ដែលមានអនុបាតចំនួនមនុស្សចាស់១០% (មនុស្សចាស់ដែលមានអាយុលើសពី៦៥ឆ្នាំ ធៀបនឹងចំនួនអ្នកនៅក្នុងកំលាំងពលកម្មដែលមានអាយុពី១៥ឆ្នាំទៅ៦៤ឆ្នាំ) បន្ទាប់មកទៀតគឺប្រទេសសឹង្ហបុរី(៩%) វៀតណាម(៧%) ម៉ាឡេស៊ី(៦%) និងឥណ្ឌូនេស៊ី និងហ្វីលីពីន(៥%ដូចគ្នា)។

## សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទំនួលបម្រុងសហព័ន្ធ

### ប្រជាជនអាមេរិកធ្វើការច្រើនម៉ោងជាងមុន ដោយទទួលបានប្រាក់កម្រៃតិចជាងមុនក្នុងកំឡុងឆ្នាំចុងក្រោយ

យោងទៅតាម [ការិយាល័យស្ថិតិផ្នែកកំលាំងពលកម្មរបស់សហរដ្ឋអាមេរិច]() ប្រាក់ចំណូលពិតជាមធ្យមប្រចាំម៉ោង មានការធ្លាក់ចុះ០,២% គិតត្រឹមចុងខែកក្កដា ឆ្នាំ២០១៨។

ទោះបីជាយ៉ាងណាក៏ដោយ ចំណូលសរុបបានកើនឡើង០,១% ដែលជាលទ្ធផលនៃការកើនឡើង០,៣%នៃសប្តាហ៍ដែលធ្វើការជាមធ្យម។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ភ្នាក់ងារស្ថិតិនឹងផ្តល់ព័ត៌មានថ្មីៗទៅអោយអ្នកសេដ្ឋកិច្ច អំពីអតិផរណានៅប្រទេសសឹង្ហបុរី ជប៉ុន និងម៉ាឡេស៊ី។ យើងក៏នឹងឃើញផងដែរអំពីតុល្យភាពថវិការបស់ប្រទេសហ្វីលីពីននៅក្នុងខែកក្កដា។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងចេញនូវសប្តាហ៍ក្រោយ៖

<u>ថ្ងៃច័ន្ទ ទី២០ ខែសីហា ឆ្នាំ ២០១៨</u>

- ផ.ស.ស នៃប្រទេសថៃសំរាប់ត្រីមាសទី២ ឆ្នាំ ២០១៨

- ការនាំចេញរបស់ប្រទេសតៃវ៉ាន់ ខែកក្កដា

<u>ថ្ងៃអង្គារ ទី២១ ខែសីហា ឆ្នាំ ២០១៨</u>

- សន្ទស្សន៍តម្លៃអ្នកផលិត នៃប្រទេសកូរ៉េខាងត្បូង សម្រាប់ខែកក្កដា
- សមតុល្យពាណិជ្ជកម្មនៃប្រទេសថៃ សម្រាប់ខែកក្កដា
- សន្ទស្សន៍ឧស្សាហកម្មទាំងអស់នៃប្រទេសជប៉ុន សម្រាប់ខែកក្កដា

<u>ថ្ងៃពុធ ទី២២ ខែសីហា ឆ្នាំ ២០១៨</u>

- API crude stock exchange នៅប្រទេសអាមេរិច សំរាប់ខែកក្កដា
- សមតុល្យពាណិជ្ជកម្មនៃប្រទេសហ្វីលីពីន សម្រាប់ខែកក្កដា
- អ្នកអត់ការងារធ្វើនៅប្រទេសតៃវ៉ាន់ សម្រាប់ខែកក្កដា

<u>ថ្ងៃព្រហស្បត្តិ៍ ទី២៣ ខែសីហា ឆ្នាំ ២០១៨</u>

- របាយការណ៍របស់គណៈកម្មាធិការទីផ្សារបើកទូលាយរបស់សហព័ន្ធ នៅអាមេរិច
- សន្ទស្សន៍សេដ្ឋកិច្ចនាំមុខរបស់ជប៉ុន ចុងក្រោយសម្រាប់ខែមិថុនា
- អតិផរណារបស់ប្រទេសសឹង្ហបុរី សម្រាប់ខែកក្កដា
- ផលិតកម្មឧស្សាហកម្មរបស់តៃវ៉ាន់ សម្រាប់ខែកក្កដា

<u>ថ្ងៃច័ន្ទ ទី២៤ ខែសីហា ឆ្នាំ ២០១៨</u>

- អតិផរណារបស់ជប៉ុន សម្រាប់ខែកក្កដា
- ផលិតកម្មឧស្សាហកម្មរបស់សឹង្ហបុរី សម្រាប់ខែកក្កដា
- អតិផរណារបស់ម៉ាឡេស៊ី សំរាប់ខែកក្កដា ។

************************